00637116

E21

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់ដើម្បីឲ្យដោះលែង អ្នកស្រី អៀង ធីរិទ្ធ ដោយឥតបង្អង់**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅសីាង

កញ្ញា Diana ELLIS QC

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

**ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានតំណាងទាំងអស់**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heure): 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស) បានចេញដីកាដំណោះស្រាយដែលត្រូវបានជូនដំណឹងដល់បណ្តាភាគី នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០[1] ។ ដីកាដំណោះស្រាយបង្គាប់ឲ្យមានការបន្តឃុំខ្លួនបណ្តោះអាសន្នសំរាប់រយៈពេលបួនខែទៀតដោយអនុលោមតាមវិធាន ៦៨ នៃវិធានផ្ទៃក្នុង[2]។ មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ **(ជនត្រូវចោទ)** បានដាក់ជូនអង្គបុរេជំនុំជម្រះ[3] នូវសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០។ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ មេធាវីការពារក្តី បានដាក់ជូននូវសារណារបស់ខ្លួន[4] ។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ (អបជ) បានសម្រេចចេញ "សាលដីលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" (សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍)[5]។ មេធាវីការពារក្តីយល់ឃើញថាចំណុចនេះមិនបានអនុលោមតាមតម្រូវការចាំបាច់ដើម្បីបង្កើតបានជា "សេចក្តីសម្រេច" ដូចមានចែងនៅវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងនោះទេ។

២. តទៅនេះ មេធាវីការពារក្តីអ្នកស្រីអៀង ធីរិទ្ធ (ជនត្រូវចោទ)សូមដាក់នូវសំណើនេះជូនអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះថា: រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នត្រូវផុតកំណត់ហើយ។ វិធាន ៦៨(៣) បានចែងថា: រយៈពេល បួន (៤)ខែ គឺជារយៈពេលអតិបរិមានៃការឃុំខ្លួន

---

[1] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 (ដីកាដំណោះស្រាយ)។

[2] កថាខណ្ឌទី ១៦១៩, ១៦២២-១៦២៤ នៃដីកាដំណោះស្រាយ ។

[3] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ដីកាដំណោះស្រាយរបស់ កសចស ដែលបានដាក់ឲ្យក្រឡាបញ្ជីនៃ កសចស ហើយគាត់ត្រូវជម្រាបភ្លាមដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ, សូមអានវិធាន ៧២(២) នៃវិធានផ្ទៃក្នុង។

[4] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ: D427/2/1 ។

[5] អបជ, សាលដីលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: D427/2/12 ។

បណ្ដោះអាសន្នដែលត្រូវអនុញ្ញាត បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយរួច ហើយនិងមុនពេលចាប់ផ្ដើមនៃការជំនុំជម្រះក្ដី ។ ដូច្នេះការបន្តឃុំខ្លួនជនត្រូវចោទតទៅទៀតគឺជាការខុសច្បាប់។

៣. តទៅនេះ មេធាវីការពារក្ដីសូមដាក់សំណើសុំឱ្យដោះលែងជនត្រូវចោទជាបន្ទាន់ និងគ្មានបង្អង់ទុកយូរទៀតបានឡើយ ដោយសារថា: វិធាន ៦៨ (២) នៃវិធានផ្ទៃដែលកំរិតរយៈពេលកំណត់៤ខែត្រូវបានផុតកំណត់ហើយ និងដោយសារថា: ការជំនុំជម្រះក្ដីប្រឆាំងនឹងជនត្រូវចោទក៏មិនទាន់ត្រូវបានកំណត់នៅឡើយដែរ។

## II **សាវតា**

៤. អាជ្ញាធរ អវតក បានចាប់ និងឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ តាំងពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧[6] ។ ដីកាដំណោះស្រាយចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ បានចោទប្រកាន់ជនត្រូវចោទនូវបទល្មើសជាតិ និងអន្តរជាតិ ហើយនិងបន្តការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទដោយផ្អែកលើវិធាន ៦៨ នៃវិធានផ្ទៃក្នុង [7]។ នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ មេធាវីការពារក្ដីបានដាក់នូវសេចក្ដីជូនដំណឹងរបស់ខ្លួនអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ មេធាវីការពារក្ដីរបស់ជនត្រូវចោទបានដាក់សារណាបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជូនអង្គបុរេជំនុំជម្រះនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០[8] ។ សហព្រះរាជអាជ្ញា (កសព) បានដាក់សេចក្ដីកត់សម្គាល់ឆ្លើយតបនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០[9] ។ ក្រោយមកទៀត មេធាវីការពារក្ដីបានដាក់សេចក្ដីសន្និដ្ឋានតបទៅនឹង

---

[6] សេចក្ដីសម្រេចឃាត់ខ្លួនរបស់ កសចស ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ឯកសារលេខ: C15 ។

[7] កថាខណ្ឌទី ១៦២២-១៦២៤ នៃដីកាដំណោះស្រាយ ។

[8] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ: D427/2/1 ។

[9] ចម្លើយតបរួមរបស់ កសព ទៅនឹង បណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារលេខ: D427/2/7 ។

សេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០[10] ។

## III. បទបញ្ញត្តិច្បាប់ពាក់ព័ន្ធ

៥. អនុលោមទៅតាមវិធាន ៦៨ នៃវិធានផ្ទៃក្នុង បានកំណត់អំពីអនុភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននៃដីកាដំណោះស្រាយ។ វិធាននេះបានចែងថា:

1. ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននិងដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬ ឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន ៦៣ និង ៦៥នៅតែតម្រូវ សហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬរក្សាលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក នៅក្នុងដីកាដំណោះស្រាយរហូតដល់ជនជាប់ចោទនេះត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង។

២. នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អានុភាពនៃសេចក្តីសម្រេចរក្សាជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តមានអានុភាពអនុវត្តរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ ។ អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងអំឡុងពេល ៤ខែ ។

៣. ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ឬ រក្សាលក្ខខណ្ឌ នៃការដាក់អោយនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ ត្រូវអស់អានុភាពក្នុងរយៈពេល ៤(បួន)ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ ។

៤. [............] ។

---

[10] សេចក្តីសន្និដ្ឋានតបរបស់មេធាវីការពារទៅនឹងចម្លើយតបរួមរបស់ កសព ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ: D427/2/11 ។

៦. មានភាពមិនច្បាស់លាស់កើតមានឡើងថាតើរយៈពេលកំណត់បួន (៤)ខែចាប់ផ្ដើមគិតពីពេលដែលដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ ឬក៏ចាប់ផ្ដើមគិតពីថ្ងៃដែលដាក់សារណាបណ្ដឹងឧទ្ធរណ៍ ហើយនេះត្រូវបានបញ្ជាក់និងបានដោះស្រាយតាមរយៈសេចក្ដីយោងទៅនឹងអត្ថបទជាភាសាបារាំងនៃវិធាន ៧៥(២)នៃវិធានផ្ទៃក្នុងបានចែងថាៈ

> *'l'Appel est formé [...]'* សំរាប់អត្ថបទជាភាសាអង់គ្លេស "សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍" ដែលមានន័យដូចគ្នាត្រូវបានប្រើនៅក្នុងវិធាន ៦៨(២) ចែងថាៈ : *'Si un appel est formé [...]'* ។

៧. ហេតុដូច្នេះ រយៈពេលបួន(៤)ខែគឺត្រូវបានគិតចាប់តាំងពីថ្ងៃដែលអង្គបុរេជំនុំជម្រះត្រូវបានគេជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ។ ម្យ៉ាងវិញទៀត ការបកស្រាយនូវចំណុចទីពីរនេះគឺវាឡូសិកផងដែរនៅពេលអានភ្ជាប់គ្នានឹងចំណុចទីបីនៃវិធាន៦៨ នៃវិធានផ្ទៃក្នុងនោះ។

៨. មាត្រា ២៤៩ នៃក្រមនីតិវិធព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាបានចែងនូវបញ្ញត្តិស្រដៀងគ្នានេះដែរ ត្រង់ផ្នែកដែលពាក់ព័ន្ធថាៈ " ប៉ុន្តែតាមសេចក្ដីសម្រេចដោយឡែក[11] នៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ [........] សេចក្ដីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្ដោះអាសន្នលែងមានអានុភាពក្នុងរយៈពេល ៤ ខែ ។ ប្រសិនបើជនត្រូវចោទមិនបានបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង"។

៩. លើសពីនេះទៀតនោះ ភាពខុសគ្នាត្រូវបានបង្កើតឡើងនៅក្នុងវិធានរវាងអង្គជំនុំជម្រះសាលាដំបូងដែលទទួលបណ្ដឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ[12] និងការជម្រះសេចក្ដីចាប់ផ្ដើមជាមួយនឹងសវនាការបឋម[13]។

---

[11] "ដីកាសម្រេចដោយឡែក" នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា គឺជាអ្វីដែល "ដីកាដំណោះស្រាយ" បានកំណត់នៅក្នុងកិច្ចដំណើរការនីតិវិធីនៃ អវតក។ សូមអានមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

[12] វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ។

[13] វិធាន ៨០ស្ទួន(១) នៃវិធានផ្ទៃក្នុង "ការជម្រះសេចក្ដីចាប់ផ្ដើមជាមួយនឹងសវនាការបឋម"។

១០. ព្រោះហេតុនោះហើយទើប ដីកាដំណោះស្រាយបានបន្តរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំតទៅទៀត[14] ប៉ុន្តែអង្គបុរេជំនុំជម្រះក៏បានខកខានមិនចេញនូវសេចក្តីសម្រេចរបស់ខ្លួនឱ្យទាន់ពេលវេលា និងទោះជាអង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះក៏ដោយ ក៏សវនាការជម្រះសេចក្តីនៅមិនទាន់បានចាប់ផ្តើមនៅឡើយទេ។ ហេតុដូច្នេះ វិធាន ៦៨ នៃវិធានផ្ទៃក្នុងត្រូវបានគេរំលោភបំពានហើយ។

## IV. សេចក្តីសន្និដ្ឋាន

១១. អនុលោមទៅតាមវិធាន ៦៨(៣) នៃវិធានផ្ទៃក្នុង បានចែងថា: ការឃុំជនត្រូវចោទបណ្តោះអាសន្ន ត្រូវបានបង្គាប់ដោយដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតត្រូវអស់អានុភាពក្នុងរយៈពេលបួន (៤) ខែក្រោយ លើកលែងតែជនត្រូវចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល បួន (៤)ខែបន្ទាប់ពីការចេញដីកាដំណោះស្រាយនោះប៉ុណ្ណោះ។ ចំណុចនេះសហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយដែរ។[15]

១២. សំណើនេះត្រូវបានដាក់នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។ រយៈពេលច្រើនជាង៤ខែត្រូវបានផុតហើយចាប់តាំងពីពេលចេញដីកាដំណោះស្រាយមក និងរយៈពេល៤ខែ ក្រោយពីការជូនដំណឹងអំពីដីកាដំណោះស្រាយដល់បណ្តាភាគីទាំងអស់រួចមក។ រយៈពេលបួន(៤)ខែបានផុតកំណត់ហើយចាប់តាំងពីមេធាវីការពារក្តីបានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួនដល់អង្គបុរេជំនុំជម្រះ ។ អនុលោមតាមវិធាន៦៨(២) និង (៣)នៃវិធានផ្ទៃក្នុង និង បទបញ្ញត្តិមាត្រា ២៤៩នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, ដីកាសម្រេចបន្តរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំតទៅទៀត ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០បានផុតកំណត់យ៉ាងយូត្រឹមថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ នេះ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អង្គបុរេជំនុំជម្រះមិនមានគុណសម្បត្តិជា "ដីកាដំណោះស្រាយស្ថាពរ" នោះបានទេ ហើយសវនាការជម្រះសេចក្តីប្រឆាំងនឹងជនត្រូវចោទក៏មិនទាន់បានចាប់ផ្តើមនៅឡើយដែរ។ អាស្រ័យហេតុនេះ គេត្រូវតែដោះលែងជនត្រូវ

---

[14] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦២៤ ។

[15] កថាខណ្ឌទី ១៦១៩ នៃដីកាដំណោះស្រាយ ។

ចោទជាបន្ទាន់ដោយគ្មានបង្អង់ដោយហេតុថាការបន្តឃុំខ្លួនតទៅទៀតនោះវាពុំមានមូលដ្ឋានណាមួយនៅក្នុងច្បាប់ឡើយ ហើយវានឹងរំលោភបំពានទៅលើសិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ ដូចដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និង លិខិតបទដ្ឋានសិទ្ធិមនុស្ស ហើយដែលតុលាការនេះត្រូវតែមានកាតព្វកិច្ចគោរពតាម។

## V សំណូមពរ

១៣. ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅខាងលើ មេធាវីការពារក្តីឲ្យជនត្រូវចោទសូមស្នើអង្គជំនុំជម្រះសាលាដំបូងដោះលែងជនត្រូវចោទឲ្យមានសេរីភាពជាបន្ទាន់ដោយគ្មានបង្អង់ ដោយស្ថិតនៅក្រោមលក្ខខណ្ឌសមហេតុផលដើម្បីឲ្យត្រូវនឹងតម្រូវការដែលមានចែងនៅក្នុងវិធាន ៦៨ នៃវិធានផ្ទៃក្នុង និង មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA |